**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

# សេចក្ដីប្រកាសព័ត៌មាន

## ស្ដីពី

## លទ្ធផលសះជានៃការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេមបូ ហៃនសាំ អិលធីឌី

ការិយាល័យអ្នកនាំពាក្យក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីមានវិវាទការងាររួមនៅក្រុមហ៊ុន **ខេមបូ ហៃនសាំ អិលធីឌី** ដែលមានកម្មករនិយោជិត ១ ៧៨៦នាក់ មានអាសយដ្ឋាន ភូមិអង្គកែវ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានចាត់តាំងមន្ត្រីជំនាញចុះសម្របសម្រួល និងដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ ចំនួន ៥លើក។

ក្រោមកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ និងស្មារតីទទួលខុសត្រូវរបស់តំណាងភាគីកម្មករនិយោជិត និងតំណាងភាគីនិយោជក នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ ភាគីទាំងពីរបានឈានដល់ការឯកភាពគ្នាលើការទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ។ ចំពោះមុខ ក្រុមហ៊ុននឹងបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជូនកម្មករនិយោជិតទាំងអស់ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង៨:០០ព្រឹក នៅទីតាំងក្រុមហ៊ុន **ខេមបូ ហៃនសាំ អិលធីឌី**។

ជាមួយគ្នានោះដែរ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានចាត់មន្ត្រីនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ដើម្បីចុះឈ្មោះរកការងារថ្មីជូនបងប្អូនកម្មករនិយោជិតផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៥រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩